ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ធំ**

-សំណុំរឿងរដ្ឋប្បវេណីលេខ: ២៩
ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩
-សញ្ញាណនៃរឿងក្តី: **ប្តឹងសុំផ្តាច់នីតិសង្វាស**
-សាលក្រមរដ្ឋប្បវេណីលេខ: **០៥"ខ"**
ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តកំពង់ធំ

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៥ ខែ**មករា** ឆ្នាំ២០២១។
-បានប្រកាសសាលក្រមនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ នៅថ្ងៃទី០២ ខែ**កុម្ភៈ** ឆ្នាំ២០២១។

**ចៅក្រមជំនុំជម្រះ**

-លោក [redacted] អនុប្រធានសាលាដំបូងខេត្តកំពង់ធំ

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ធំ

- **បានឃើញ**: សំណុំរឿងរដ្ឋប្បវេណីលេខៈ ២៩ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តកំពង់ធំ។

-**បានឃើញ**: កំណត់ហេតុស្តីពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ធំ។

-**ដើមចោទ**: ឈ្មោះ [redacted] **ស៊ាងលីម** ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ: ភូមិ [redacted] មុខរបរលក់ដូរ ប្តីឈ្មោះ [redacted] ស៊ីណាន មានកូន ០២នាក់ ឪពុកឈ្មោះ [redacted] សាន (រស់) ម្តាយឈ្មោះ [redacted] **យូអេង** (រស់) ។

-**មេធាវីតំណាងដោយអាណត្តិ**: គ្មាន ។

-**ចុងចម្លើយ**: ឈ្មោះ [redacted] **ស៊ីណាន** ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ: ភូមិ [redacted] មុខរបរជាងភ្លើង ប្រពន្ធឈ្មោះ [redacted] ស៊ាងលីម មានកូន០២នាក់ ឪពុកឈ្មោះ [redacted] គង់(រស់) ម្តាយឈ្មោះ [redacted] ហាក់(រស់) ។

-**មេធាវីតំណាងដោយអាណត្តិ**: លោកស្រី [redacted]។

**អង្គហេតុ និងចំណុចវិវាទ**

១-**ការទាមទារ**: ក្នុងរឿងក្តីនេះ ដើមចោទ ប្តឹងទាមទារសុំឱ្យតុលាការចេញសាលក្រមដូចខាងក្រោម:

ក-សុំផ្តាច់នីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] **ស៊ីណាន**។

ខ-សុំអំណាចមេបាលើកូនឈ្មោះ [redacted] គីមលាង ភេទស្រី កើតឆ្នាំ២០១៣ និងកូនឈ្មោះ [redacted] គីមហុង ភេទប្រុស កើតឆ្នាំ២០១៤ ។

គ-សុំរ៉ាប់រងប្រាក់ប្រដាប់ក្តីតុលាការ និងពន្ធផ្សេងៗដោយខ្លួនឯង។

**២-ការពន្យល់ត្រួសៗអំពីអង្គន័យនៃរឿងក្តី**

នៅក្នុងរឿងក្តីនេះ ដើមចោទឈ្មោះ [redacted] ស៊ាងលីម ប្តឹងសុំផ្តាច់នីតិសង្វាសពីប្តីឈ្មោះ [redacted] ស៊ីណាន ព្រោះខ្លួនអស់មនោសញ្ចេតនានឹងបន្តរួមរស់ជាមួយប្តីទៀតហើយ និងគ្មានសង្ឃឹមថានឹងអាចធ្វើការផ្សះផ្សាគ្នាឱ្យបានល្អឡើងវិញនោះទេ ទើបខ្លួនដាក់ពាក្យបណ្តឹងមកតុលាការ។ ខ្លួនប្តឹងសុំអំណាចមេបាលើកូនឈ្មោះ [redacted] គីមលំង ភេទស្រី កើតឆ្នាំ២០១៣ និងកូនឈ្មោះ [redacted] គីមហុង ភេទប្រុស កើតឆ្នាំ២០១៤ ព្រោះខ្លួនអាចមើលថែកូនទាំងពីរនាក់បាន ហើយខ្លួនមិនទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនពីប្តីនោះទេ។

**៣-ការអះអាងរបស់ភាគីនាពេលទាញហេតុផលផ្ទាល់មាត់**

**-ចុងចម្លើយ៖** ឈ្មោះ [redacted] **ស៊ីណាន** បានធ្វើសេចក្តីថ្លែងការណ៍ប្តឹងសុំនាពេលទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្ញុំបាទនៅតែឯកភាពលែងលះជាមួយប្រពន្ធឈ្មោះ [redacted] ស៊ាងលីម ព្រោះប្រពន្ធរូបនេះមានសាហាយ(កូនរបស់ខ្ញុំបានប្រាប់យ៉ាងដូច្នេះ) ហើយរហូតមកដល់ពេលនេះ ខ្ញុំបាទក៏អស់មនោសញ្ចេតនានឹងបន្តរួមរស់ជាមួយប្រពន្ធរូបនេះទៀតហើយ។ ខ្ញុំបាទមិនឯកភាពប្រគល់អំណាចមេបាលើកូនទាំងពីរនាក់ ឱ្យទៅប្រពន្ធឡើយ ព្រោះកន្លងមកប្រពន្ធរូបនេះមិនចេះមើលថែកូនទេ ហើយមិនបានយកចិត្តទុកដាក់លើអនាគតកូនទាំងពីរនាក់ទេ។ ខ្ញុំបាទប្តឹងសុំអំណាចមេបាលើកូនទាំងពីរនាក់ ព្រោះខ្ញុំបាទអាចមើលថែកូនដោយខ្លួនឯងបាន ហើយខ្ញុំបាទអាចឱ្យកូនសិក្សាខ្ពង់ខ្ពស់ និងរស់នៅក្នុងសង្គមប្រកបដោយភាពត្រឹមត្រូវ និងក្លាយជាពលរដ្ឋល្អ។ កន្លងមកកូនទាំងពីរនាក់រស់នៅជាមួយខ្ញុំបាទប្រកបដោយសេចក្តីសុខនិងសុភមង្គល ចំណែកឯប្រពន្ធមិនមានលទ្ធភាពចិញ្ចឹមកូនឱ្យបានល្អប្រសើរឡើយ ព្រោះកន្លងមកប្រពន្ធរូបនេះមិនដែលមើលថែកូនដោយខ្លួនឯងទេ គឺតែងតែយកកូនទៅផ្ញើម្តាយគាត់ ឯគាត់ទៅបាត់ពីផ្ទះជាញឹកញាប់។ ខ្ញុំបាទសូមបញ្ជាក់ថា កូនរបស់ខ្ញុំបាទទាំងពីរនាក់រស់នៅជាមួយខ្ញុំ មុនពេលដែលប្រពន្ធខ្ញុំបាទប្តឹងសុំលែងលះពីខ្ញុំមកម្លេះ តែស្រាប់តែនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ខ្ញុំបាទបាននាំកូនទាំងពីរនាក់ទៅហែកបិននៅវត្តក្រូច ស្ថិតនៅភូមិក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ស្រាប់តែពេលនោះប្រពន្ធរបស់ខ្ញុំបាទបានមកលួចយកកូនស្រី០១នាក់របស់ខ្ញុំបាទឈ្មោះ [redacted] គីមលំង កើតឆ្នាំ២០១៣ ទៅបាត់តែម្តង ដោយគ្មានឱ្យដំណឹងមកខ្ញុំបាទទាល់តែសោះ ដែលធ្វើឱ្យខ្ញុំបាទភិតភ័យយ៉ាងខ្លាំង ហើយរហូតមកដល់ពេលនេះ ខ្ញុំបាទមិនដឹងសុខទុក្ខរបស់កូនខ្ញុំបាទយ៉ាងណាទេ។ ខ្ញុំបាទមិនទាមទារអាហារកាតព្វកិច្ចពីប្រពន្ធនោះឡើយ។ ខ្ញុំបាទនិងប្រពន្ធពិតជាគ្មានទ្រព្យសម្បត្តិរួម និងបំណុលរួមជាមួយគ្នាប្រាកដមែន។

**-សាក្សី ៖** ឈ្មោះ [redacted] **គង់** (សាក្សីរបស់ចុងចម្លើយ) បានធ្វើសេចក្តីថ្លែងការណ៍បំភ្លឺនាពេលទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្ញុំបាទត្រូវជាឪពុករបស់ឈ្មោះ [redacted] ស៊ីណាន ។ កន្លងមកកូនប្រសាររបស់ខ្ញុំបាទឈ្មោះ [redacted] ស៊ាងលីម និងកូនបង្កើតរបស់ខ្ញុំបាទបានស្នាក់នៅជាមួយខ្ញុំបាទនិងគ្រួសារតែម្តង គឺរហូតដល់ពួកគេមានកូន០២នាក់ជាមួយគ្នា។ ស្រាប់តែនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ កូនប្រសាររបស់ខ្ញុំបាទឈ្មោះ [redacted] ស៊ាងលីម បានរត់ចេញពីផ្ទះ ហើយប្រាប់ខ្ញុំបាទថា ចង់លែងលះជាមួយកូនបង្កើតរបស់ខ្ញុំតែម្តង ដោយគ្មានមូលហេតុសមស្របទាល់តែសោះ។ ចំពោះចៅទាំងពីរនាក់របស់ខ្ញុំបាទគឺរស់នៅជាមួយកូនប្រុសរបស់ខ្ញុំ និងគ្រួសាររបស់ខ្ញុំប្រកបដោយសុភមង្គល ព្រោះខាងគ្រួសាររបស់ខ្ញុំបាទមានលទ្ធភាព និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទំនុកបម្រុងចិញ្ចឹមចៅទាំងពីរនាក់យ៉ាងពេញលេញ និងឱ្យរៀនសូត្រជាប្រចាំ។ ខ្ញុំបាទសូមបញ្ជាក់ថា ចៅទាំងពីរនាក់របស់ខ្ញុំបាទបានរស់នៅជាមួយខ្ញុំ និងកូនបង្កើត តាំងពីមុនពេលដែលកូនប្រសាររបស់ខ្ញុំបាទប្តឹងសុំលែងលះពីកូនរបស់ខ្ញុំ

បាទមកម្លេះ ទើបតែនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ខ្ញុំបាទបាននាំចៅទាំងពីរនាក់ទៅហែកបិននៅវត្តក្រូច ស្ថិតនៅភូមិក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ស្រាប់តែកូនប្រសាររបស់ខ្ញុំបាទបានមកលួចយកចៅរបស់ខ្ញុំ ឈ្មោះ [redacted] គីមល័ង ភេទស្រី ទៅបាត់តែម្តង ដោយគ្មានឱ្យដំណឹងអ្វីទាំងអស់ ដែលបង្កឱ្យមានភាពឆោឡោ និងភិតភ័យយ៉ាងខ្លាំងពីសំណាក់ពួកខ្ញុំបាទ។ បច្ចុប្បន្ននេះ ចៅរបស់ខ្ញុំបាទឈ្មោះ [redacted] គីមហុង កំពុងស្នាក់នៅជាមួយកូនបង្កើតរបស់ខ្ញុំ និងគ្រួសារខ្ញុំបាទ ប្រកបដោយសេចក្តីសុខ និងកំពុងរៀនសូត្រយ៉ាងល្អ។

**-សាក្សី** ៖ ឈ្មោះ [redacted] **សំណាង** (សាក្សីរបស់ចុងចម្លើយ) បានធ្វើសេចក្តីថ្លែងការណ៍បំភ្លឺនាពេលទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្ញុំបាទសូមជម្រាបជូនតុលាការមេត្តាជ្រាបថា ខ្ញុំបាទត្រូវជាប្អូនថ្លៃរបស់ឈ្មោះ [redacted] ស៊ីណាន ហើយកន្លងមកក្មួយទាំងពីរនាក់របស់ខ្ញុំបាទបានរស់នៅជាមួយឈ្មោះ [redacted] ស៊ីណាន មុនពេលដែលឈ្មោះ [redacted] ស៊ាងលីម បានប្តឹងសុំលែងលះពីគាត់ឯណោះ ហើយស្រាប់តែនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ពួកយើងបានទៅហែកបិននៅវត្តក្រូច ស្ថិតនៅភូមិក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ស្រាប់តែឈ្មោះ [redacted] ស៊ាងលីម បានមកលួចយកក្មួយរបស់ខ្ញុំបាទទាំងកំហឹង បើទោះបីជាក្មួយរបស់ខ្ញុំបាទបានបដិសេធ និងស្រែកយំ មិនព្រមទៅជាមួយយ៉ាងណាក៏ដោយ។ ខ្ញុំបាទសូមបញ្ជាក់ថា កន្លងមក ក្មួយទាំងពីរនាក់របស់ខ្ញុំបាទរស់នៅជាមួយឈ្មោះ [redacted] ស៊ីណាន ប្រកបដោយសុភមង្គល ហើយបានរៀនសូត្រជាប្រចាំ ព្រោះឈ្មោះ [redacted] ស៊ីណាន មានសមត្ថភាពចិញ្ចឹមកូនដោយពេញលេញ។ បច្ចុប្បន្ននេះ នៅសល់តែក្មួយម្នាក់ទៀតឈ្មោះ [redacted] គីមហុង ភេទប្រុស តែប៉ុណ្ណោះ ដែលកំពុងរស់នៅជាមួយឈ្មោះ [redacted] ស៊ីណាន ហើយរស់នៅដោយសុខស្រួលផងដែរ។

**-សាក្សី** ៖ ឈ្មោះ [redacted] **ឌុទ្ធី** (សាក្សីរបស់ចុងចម្លើយ) បានធ្វើសេចក្តីថ្លែងការណ៍បំភ្លឺនាពេលទាញហេតុផលដោយផ្ទាល់មាត់ថា៖ ខ្ញុំបាទជាមេភូមិតាំងគោក ឃុំសូយោង ស្រុកតាំងគោក ខេត្តកំពង់ធំ។ ខ្ញុំបាទដឹងថា ឈ្មោះ [redacted] ស៊ីណាន បានមើលថែកូនយ៉ាងល្អប្រសើរ ដោយក្មេងទាំងពីរនាក់បានរៀនសូត្រត្រឹមត្រូវ ហូបចុកបានល្អ និងទទួលបានការមើលថែយ៉ាងល្អពីឈ្មោះ [redacted] ស៊ីណាន។ កន្លងមក ក្មេងទាំងពីរនាក់បានរស់នៅជាមួយឈ្មោះ ង៉ិន ស៊ីណាន មុនពេលដែលឈ្មោះ សេន ស៊ាងលីម បានប្តឹងសុំលែងលះពីគាត់ឯណោះ។ ចំពោះលិខិតបញ្ជាក់ ធ្វើនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ គឺជាលិខិតដែលខ្ញុំបាទបានធ្វើប្រាកដមែន ព្រោះខ្ញុំបាទជាមេភូមិ ហេតុនេះ ស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋយ៉ាងណាគឺខ្ញុំបានដឹងច្រើននិងច្បាស់លាស់ផងដែរ។

**-ដើមចោទ**៖ ឈ្មោះ [redacted] **ស៊ាងលីម** ពុំមានវត្តមាននាពេលទាញហេតុផលដោយផ្ទាល់មាត់ទេ។

**-សំណូមពរ**៖

**-ចុងចម្លើយ**៖ ឈ្មោះ [redacted] **ស៊ីណាន** ៖ ខ្ញុំបាទសូមឱ្យតុលាការសម្រេចតាមការប្តឹងសុំរបស់ខ្ញុំបាទ។

**ចំណុចវិវាទ:**

-ការប្តឹងសុំអំណាចមេបាលើកូនឈ្មោះ [redacted] គីមល័ង និងកូនឈ្មោះ [redacted] គីមហុង របស់គូភាគី។

-ក្រោយពីបានឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍ និងសំណូមពររបស់ចុងចម្លើយ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍បំភ្លឺរបស់សាក្សី

-ក្រោយពីបានពិនិត្យភស្តុតាងជាសម្ភារីធីក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ។



Scanned with CamScanner

## សាលាដំបូងខេត្តកំពង់ធំ

## សំអាងហេតុ

តាមលទ្ធផលនៃការស្តាប់សេចក្តីថ្លែងការណ៍របស់ចុងចម្លើយ និងសេចក្តីថ្លែងការណ៍បំភ្លឺរបស់សាក្សី រួមទាំងការពិនិត្យភស្តុតាងពាក់ព័ន្ធជាឯកសារក្នុងសំណុំរឿងរួចមកៈ

-**យល់ឃើញថាៈ** ពាក្យបណ្តឹងចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១៩ របស់ដើមចោទឈ្មោះ [redacted] ស៊ាងលីម មានលក្ខណៈត្រឹមត្រូវតាមទម្រង់ គប្បីតុលាការទទួលមកពិនិត្យ និងសម្រេច។

-**យល់ឃើញថាៈ** តាមសំបុត្រអាពាហ៍ពិពាហ៍លេខៈ ១០ សៀវភៅអាពាហ៍ពិពាហ៍លេខៈ០១/២០១២ ឆ្នាំ២០១២ ធ្វើនៅសូរគង ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ចេញដោយមេឃុំសូរគង ស្រុកកងមាស ខេត្តកំពង់ចាម បញ្ជាក់ឱ្យឃើញថាៈ ឈ្មោះ [redacted] ស៊ីណាន និងឈ្មោះ [redacted] ស៊ាងលីម ពិតជាប្តីប្រពន្ធស្របច្បាប់ដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមបញ្ញត្តិមាត្រា៩៥៥ នៃក្រមរដ្ឋប្បវេណីប្រាកដមែន។

-**យល់ឃើញថាៈ** តាមសេចក្តីថ្លែងការណ៍របស់ដើមចោទឈ្មោះ [redacted] ស៊ាងលីម បានថ្លែងការណ៍នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថាៈ ខ្លួនប្តឹងសុំលែងលះពីប្តីឈ្មោះ [redacted] ស៊ីណាន ព្រោះខ្លួនអស់មនោសញ្ចេតនានឹងបន្តរួមរស់ជាមួយប្តីរូបនេះទៀតហើយ ហើយកន្លងមកប្តីរូបនេះមិនដែលមើលថែរូបខ្លួននោះទេ ហើយក៏មិនដែលយកចិត្តទុកដាក់ចំពោះខ្លួនដែរ។ **គប្បីតុលាការពិចារណា។**

-**យល់ឃើញថាៈ** តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] ស៊ីណាន បានធ្វើសេចក្តីថ្លែងការណ៍នាពេលទាញហេតុផលដោយផ្ទាល់មាត់ថាៈ ខ្លួនឯកភាពលែងលះជាមួយប្រពន្ធឈ្មោះ [redacted] ស៊ាងលីម ព្រោះប្រពន្ធរូបនេះមានសាហាយ(កូនខ្លួនបានប្រាប់យ៉ាងដូច្នេះ) ហើយរហូតមកដល់ពេលនេះ ខ្លួនក៏អស់មនោសញ្ចេតនានឹងបន្តរួមរស់ជាមួយប្រពន្ធរូបនេះទៀតហើយដែរ។ **គប្បីតុលាការពិចារណា។**

-**យល់ឃើញថាៈ** តាមសេចក្តីថ្លែងការណ៍របស់គូភាគី **តុលាការជឿជាក់ថា** ដើមចោទឈ្មោះ [redacted] ស៊ាងលីម និងចុងចម្លើយឈ្មោះ [redacted] ស៊ីណាន ពិតជារស់នៅមិនចុះសម្រុងនឹងគ្នាប្រាកដមែន ដែលមិនអាចឱ្យគូភាគីបន្តរួមរស់ជាមួយគ្នាជាប្តីប្រពន្ធប្រកបដោយសុភមង្គលទៀតទេ ហើយចំណងអាពាហ៍ពិពាហ៍របស់គូភាគីពិតជាមិនអាចធ្វើបដិទានឱ្យបានល្អឡើងវិញឡើយ ហេតុដូច្នេះ គប្បីតុលាការសម្រេចឱ្យគូភាគីផ្តាច់នីតិសង្វាសពីគ្នា តាមបញ្ញត្តិមាត្រា៩៧៨នៃក្រមរដ្ឋប្បវេណី។

-**យល់ឃើញថាៈ** តាមបញ្ញត្តិមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណីៈ អំឡុងពេលហាមឃាត់មិនឱ្យរៀបអាពាហ៍ពិពាហ៍ កថាខណ្ឌ១ បញ្ញត្តិថាៈ **នារីពុំអាចរៀបអាពាហ៍ពិពាហ៍ថ្មីទៀតឡើយ ប្រសិនបើអំឡុងពេល ១២០(មួយរយម្ភៃ)ថ្ងៃ ពុំទាន់បានកន្លងផុត គិតចាប់ពីថ្ងៃដែលអាពាហ៍ពិពាហ៍មុន ត្រូវបានរំលាយ ឬលុបចោល។** តាមបញ្ញត្តិច្បាប់ខាងលើ គប្បីតុលាការហាមឃាត់ដើមចោទឈ្មោះ [redacted] ស៊ាងលីម មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី នៅក្នុងអំឡុងពេល ១២០(មួយរយម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ។

-**យល់ឃើញថាៈ** នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល, ដើមចោទឈ្មោះ [redacted] ស៊ាងលីម បានប្តឹងសុំអំណាចមេបាលើកូនឈ្មោះ [redacted] គីមល័ង ភេទស្រី និងកូនឈ្មោះ [redacted] គីមហុង ភេទប្រុស ដោយអះអាងថា ខ្លួនអាចមើលថែកូនដោយខ្លួនឯងបាន ហើយម្យ៉ាងវិញទៀត ខ្លួនមានមនោសញ្ចេតនាយ៉ាងខ្លាំងជាមួយកូន។ **គប្បីតុលាការពិចាណា។**



Scanned with CamScanner

-យល់ឃើញថា: តាមសេចក្តីថ្លែងការណ៍របស់ចុងចម្លើយឈ្មោះ [redacted] ស៊ីណាន បានថ្លែងការណ៍ប្តឹងសុំនាពេលទាញហេតុផលដោយផ្ទាល់មាត់ថា: ខ្លួនមិនឯកភាពប្រគល់អំណាចមេបាលើកូនឈ្មោះ [redacted] គីមល័ង ភេទស្រី និងកូនឈ្មោះ [redacted] គីមហុង ភេទប្រុស ឱ្យទៅប្រពន្ធរូបនេះឡើយ ព្រោះប្រពន្ធរូបនេះមិនចេះមើលថែកូន ហើយមិនដែលយកចិត្តទុកដាក់លើអនាគតកូនទាំងពីរនាក់ឡើយ។ ខ្លួនប្តឹងសុំអំណាចមេបាលើកូនទាំងពីរនាក់ ព្រោះខ្លួនអាចមើលថែកូនដោយខ្លួនឯងបាន ហើយខ្លួនអាចឱ្យកូនសិក្សាខ្ពង់ខ្ពស់ និងរស់នៅក្នុងសង្គមប្រកបដោយភាពត្រឹមត្រូវ និងក្លាយជាពលរដ្ឋល្អ។ **គប្បីតុលាការពិចាណា។**

**-យល់ឃើញថា:** តាមសេចក្តីថ្លែងការណ៍បំភ្លឺរបស់សាក្សីឈ្មោះ [redacted] គង់, សាក្សីឈ្មោះ [redacted] សំណាង និងសាក្សីឈ្មោះ [redacted] វុទ្ធី បានឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នានាពេលទាញហេតុផលដោយផ្ទាល់ថា: កូនៗទាំងពីរនាក់ខាងលើបានរស់នៅជាមួយចុងចម្លើយឈ្មោះ [redacted] ស៊ីណាន ប្រកបដោយសុភមង្គល និងទទួលបានការរៀនសូត្រជាប្រចាំ ហើយកន្លងមក កូនទាំងពីរនាក់នេះបានរស់នៅជាមួយចុងចម្លើយនៅមុនពេលដែលដើមចោទឈ្មោះ [redacted] ស៊ាងលីម ប្តឹងសុំលែងលះពីចុងចម្លើយឯណោះ ស្រាប់តែនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ កូនទាំងពីរនាក់បានទៅចូលរួមហែកឋិននៅវត្តក្រូច ស្ថិតនៅភូមិក្រូច ឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ស្រាប់តែពេលនោះ ឈ្មោះ [redacted] ស៊ាងលីម បានមកលួចយកកូនស្រី០១នាក់ ឈ្មោះ [redacted] គីមល័ង កើតឆ្នាំ២០១៣ ទៅបាត់តែម្តង។ **គប្បីតុលាការពិចារណា។**

**-យល់ឃើញថា:** តាមលិខិតបញ្ជាក់ ធ្វើនៅតាំងគោក ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ចេញដោយមេភូមិតាំងគោក បានបញ្ជាក់ថា ឈ្មោះ [redacted] ស៊ីណាន បានយកកូនពីរនាក់ (កូនទី១ឈ្មោះ [redacted] គីមល័ង ភេទស្រី និងកូនទី២ឈ្មោះ [redacted] គីមហុង ភេទប្រុស) មកចិញ្ចឹមថែទាំបានល្អ និងឱ្យរៀនសូត្រ។ ក្រោយមក នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ឈ្មោះ [redacted] ស៊ីណាន បាននាំកូនទាំងពីរនាក់ទៅធ្វើបុណ្យនៅឃុំក្រូច ស្រុកព្រៃឈរ ខេត្តកំពង់ចាម ក៏បានជួបម្តាយ ហើយម្តាយសុំមើលកូនបន្តិច រួចក៏ចាប់អោបកូនស្រីទៅបាត់ រហូតដល់សព្វថ្ងៃនេះទៅ។ **គប្បីតុលាការពិចារណា។**

**-យល់ឃើញថា:** កូនៗរបស់គូភាគីមានឈ្មោះ [redacted] **គីមល័ង** ភេទស្រី កើតឆ្នាំ២០១៣ និងកូនឈ្មោះ [redacted] **គីមហុង** ភេទប្រុស កើតឆ្នាំ២០១៤ នៅជាអនីតិជននៅឡើយ ហេតុដូច្នេះ គប្បីតុលាការសម្រេចលើការប្តឹងសុំអំណាចមេបាលើកូនទាំងពីរនាក់ខាងលើ។

**-យល់ឃើញថា:** ក្រោយពីបានស្តាប់សេចក្តីការណ៍របស់ចុងចម្លើយ រួមទាំងសេចក្តីថ្លែងការណ៍បំភ្លឺរបស់សាក្សីនាពេលទាញហេតុផលដោយផ្ទាល់មាត់ និងតាមការពិនិត្យភស្តុតាងក្នុងសំណុំរឿងរួចមក **តុលាការជឿជាក់ថា:** ចុងចម្លើយឈ្មោះ [redacted] **ស៊ីណាន** ពិតជាមានលទ្ធភាពគ្រប់គ្រាន់ និងមានលក្ខណៈសម្បត្តិជាអាណាព្យាបាលដ៏សមស្រប ក្នុងការចិញ្ចឹមបីបាច់ថែរក្សាកូនទាំងពីរនាក់ឱ្យបានល្អប្រសើរ ទាំងជីវភាព និងការសិក្សាប្រាកដមែន ដែលអាចជាឧត្តមប្រយោជន៍ដល់កូនទាំងពីរនាក់ខាងលើ ហេតុដូច្នេះ គប្បីតុលាការសម្រេចប្រគល់អំណាចមេបាលើកូនទាំងពីរនាក់ខាងលើ ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **ស៊ីណាន** ។

**-យល់ឃើញថា:** ភាគីដែលមិនបានទទួលអំណាចមេបា អាចមានសិទ្ធិចូលរួមថែរក្សា និងឧបត្ថម្ភដល់កូនទាំងពីរនាក់ផងដែរ ស្របតាមបញ្ញត្តិមាត្រា១០៤០ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី ដែលបញ្ញត្តិថា ឪពុកឬម្តាយដែលពុំមានអំណាចមេបាលើកូន អាចចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនបាន។



Scanned with CamScanner

-យល់ឃើញថា: តាមសេចក្តីថ្លែងការណ៍របស់គូភាគី ឃើញថាភាគីពុំប្តឹងសុំអាហារកាតព្វកិច្ចចិញ្ចឹមកូននោះទេ ហេតុដូច្នេះ តុលាការមិនពិចារណាត្រង់ចំណុចនេះឡើយ។

-យល់ឃើញថា: តាមសេចក្តីថ្លែងការណ៍របស់គូភាគី ឃើញថាគូភាគីពុំមានទ្រព្យសម្បត្តិរួម និងបំណុលរួមជាមួយគ្នានោះទេ ហេតុដូច្នេះ តុលាការមិនពិចារណាឡើយ។

-យល់ឃើញថា: នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឃើញថា: ដើមចោទប្តឹងសុំរ៉ាប់រងប្រាក់ប្រដាប់ក្តី និងពន្ធផ្សេងៗដោយខ្លួនឯង។ គប្បីតុលាការពិចារណា ។

## <u>សេចក្តីសម្រេចបញ្ចប់</u>

១-ឱ្យដើមចោទឈ្មោះ [redacted] **ស៊ាងលីម** និងចុងចម្លើយឈ្មោះ [redacted] **ស៊ីណាន** ផ្តាច់នីតិសង្វាសពីគ្នា ចាប់ពីពេលដែលសាលក្រមនេះចូលជាស្ថាពរ។

២-ហាមឃាត់ដើមចោទឈ្មោះ [redacted] **ស៊ាងលីម** មិនឱ្យរៀបអាពាហ៍ពិពាហ៍ថ្មី នៅក្នុងអំឡុងពេល ១២០ (មួយរយម្ភៃ)ថ្ងៃ គិតចាប់ពីថ្ងៃដែលសាលក្រមនេះចូលជាស្ថាពរ តាមបញ្ញត្តិមាត្រា ៩៥០ នៃក្រមរដ្ឋប្បវេណី។

៣-ប្រគល់អំណាចមេបាលើកូនឈ្មោះ [redacted] **គីមល័ង** ភេទស្រី និងកូនឈ្មោះ [redacted] **គីមហុង** ភេទប្រុស ឱ្យទៅចុងចម្លើយឈ្មោះ [redacted] **ស៊ីណាន** ។ ភាគីដែលពុំមានអំណាចមេបា ក្រោយពេលលែងលះមានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូនស្របតាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៤-ប្រាក់ប្រដាប់ក្តីតុលាការ និងពន្ធផ្សេងៗជាបន្ទុករបស់ដើមចោទ។

៥-សាលក្រមនេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៥ ខែមករា ឆ្នាំ២០២១ និងប្រកាសនៅសាលសវនាការនៃសាលាដំបូងខេត្តកំពង់ធំ នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១ ចំពោះមុខចុងចម្លើយឈ្មោះ [redacted] **ស៊ីណាន** និងកំបាំងមុខដើមចោទឈ្មោះ [redacted] **ស៊ាងលីម** ។

ទុកសិទ្ធិឱ្យភាគីអវត្តមានប្តឹងទាស់ និងទុកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់ពីកាលបរិច្ឆេទដែលភាគីបានទទួលនូវអនុសារ សាលក្រមនេះ។

ថ្ងៃអង្គារ ៥រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ខេត្តកំពង់ធំ, ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១
**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា: [redacted]

---

"**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**"
ថ្ងៃអង្គារ ៥រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ខេត្តកំពង់ធំ, ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២១
**ក្រឡាបញ្ជីសវនាការ**

**បានឃើញ និងឯកភាព**
**ចៅក្រមជំនុំជម្រះ**

[redacted]

[redacted]